# ១៩ ~រឿង ចៅផុងចៅសាញ់

បពិត្រអញខ្ញុំហត្ថាបង្គំប្រណម្យវន្ទា សូមមានតេជៈដូចព្រះរាមា សូមមានប្រាជ្ញាដូចព្រះមហោសថ ។ ខ្ញុំថ្វាយបង្គំព្រះពុទ្ធឧត្តមប្រាជ្ញាមោះមុតតែងនាំសត្វផងឆ្លាស់ឆ្លងសមុទ្រ សង្សារចំហុតដាក់ដល់សួគ៌ា ។ ព្រះអង្គត្រាស់ត្រេចសាងសម្ភារស្រេចផ្តាច់សង្សារវាលើកលែងត្រៃភពសាយសព្វទិស ស្តេចផ្ចាញ់រាមាដល់និព្វានហោង ។ បង្គំព្រះពុទ្ធបារមី ពិសុទ្ធពិសេសឥតហ្មងពន្លឺរស្មីភ្លឺក្រៃកន្លង ដល់សួគ៌នាយហោងភ្លឺផ្លេកសព្វស្ថាន ។ បង្គំព្រះធម៌ពិសេស មានអាថ៌ជ្រៅពន់ប្រមាណ អាចតែងក្រងរងសត្វផង សព្វស្ថានជាខ្លឹមប្រធានត្រៃពិធសម្បត្តិ ។ បង្គំព្រះសង្ឃប្រសើរសឹងទ្រង់សីលសុទ្ធមធ្យ័តជាស្រូវស្រែបុណ្យ មានគុណគាប់ក្តាត់ តាមផ្លូវប្រតិបត្តិព្រះសង្ឃទាំងឡាយ ។ លោកខំសង្វាតយកបិណ្ឌបាតប្រោសសត្វកម្ចាយអោយអស់ទុក្ខភ័យទោសពៃរ៍ក្នុងកាយសត្វផងទាំងឡាយតាមសទ្ធាហោង ។

នេះនឹងស្រដីបុរសប្រុសស្រីពីរនាក់ជាម្តង ប្តី និង ប្រពន្ធឥតធនធានផង ឥតញាតិសោតផងឥតផៅសន្តាន ។ រកស៊ីនៅនាក្នុងព្រៃព្រឹក្សាយូរទៅ ទើបបានកាប់ឈើព្រៃនៅព្រៃស្មសាន បន្តិចទើបបានចម្ការមួយហោង ។ នោះឯងធំក្រៃប្រមាណនោះនៃប្រាំសិនជាម្តង ជាអ្នកកំសត់ទុគ៌តកន្លង ទាំងពីរនាក់ហោងត្រេកអរពេកក្រៃ ។ លុះដាំស្រូវទៅក្នុងចំការកូវស្រូវនោះប្រពៃ នឹកថាស្រូវអញនេះពេញល្អក្រៃគុម្ពធំណាស់នៃលើសស្រូវអ្នកផង ។ ជាយូរលង់ទៅរីឯដើមស្រូវនោះសោតហោងល្អៗក្រៃលែងកួរវែងកន្លងជាក់កួរល្តាយល្អងទន់តាមគ្នា ។ ល្អល្អះប្រពៃរីស្រូវនោះនៃទុំពេញចំការរន្ទាលប្រាលឆ្អៅ ផ្លែស្រូវនោះណាំពាសពេញចំការ បរិបូណ៌ជាត្រើយ ។ រីឯបុរសទាំងពីរស្មានស្មោះបបួលគ្នាហើយទៅច្រូតនៃស្រូវនោះកូវជាត្រើយយកស្រូវមកហើយដាក់លើផ្ទះហោង ។ លុះដល់រដូវ នាំគ្នាយកស្រូវទៅដាំទៀតផ្គង ដូចកាលសព្វគ្រាពីដើមនោះផងស្រូវនោះឯងហោងល្អដូចដើមនៃ ។ យូរលង់ទៅណាំ បានភោជន៍ផល្លាវិតតែច្រើនក្រៃពេញបរិបូណ៌ណាស់ឥតខ្វះឡើយនៃត្រេកអរក្រៃធ្វើជង្រុកឯង ។ មួយនោះធំក្រៃហើយ



វែងផងនៃប្រាកដជាក់ស្តែងធេងធំទូលាយខ្ពស់ក្រៃគួរស្ញែងជង្រុកប្រាំល្វែង ឥតក្រែងអ្នកផង ។ ជាយូរទៅណាំនាងមានកូនងាំមួយល្អកន្លង អោយឈ្មោះអាសាញ់ធំពេញចិត្តហោង ស៊ីបាយច្រើនផងមួយឆ្នាំងមួយថ្ងៃ ។ លុះដល់គំរប់ប្រាំមួយដណ្តប់ឆ្នាំហើយសោតនៃបរិភោគអាហារកាន់តែច្រើនក្រៃនាក្នុងមួយថ្ងៃបីថាំងអង្ករ ។ រីឯម្តាយឪពុកចេះតែកើតទុក្ខភ័យតែពីក្រ រីស្រូវក្នុងស្រែកកាន់តែមិនល្អ ភ័យតែពីក្រធ្វើស្រូវមិនទាន់ ។ ទើបមកគិតគ្នា បើខ្ញុំទុកវាឃើញជាមិនគ្រាន់ ពីដើមយើងមានឥឡូវយើងកាន់តែថយជាក់ស្បាន់ សម្បត្តិហិនក្រ ។ រីស្រូវក្នុងស្រែយូរឆ្នាំហើយនៃកាន់តែមិនល្អ ទុកវាធ្វើអ្វីនាំអោយតែក្រសំលាប់អោយមរណ៍អាចោរចង្រៃ ។

## បទព្រហ្មគីតិ

ឪពុកហៅកូនហើយ អាសាញ់អើយមកអោយឆាប់
ត្បិតអញចង់ទៅកាប់ ឈើងព្រៃភ្នំនោះណាំ ។
អាសាញ់បានឮហើយ ដើរព្រងើយប្រាប់មាតា
ថាម៉ែដាំបាយវ៉ា ត្បិតខ្ញុំទៅកាប់ឈើផង ។
ម្តាយឮអាសាញ់ប្រាប់ ដាំបាយឆាប់ពេកកន្លង
ខ្ចប់អោយអាសាញ់ហោង ហើយអាសាញ់ស្ពាយដើរវៃ ។
ឪពុកថាអាសាញ់ ខំដើរខ្ចាញ់អាចង្រៃ
ហើយក្រែងមិនទាន់ថ្ងៃ នឹងវិលរឹងមិនទាន់ហោង ។
លុះចរយាត្រាទៅ ដល់ព្រៃជ្រៅដុតដែនដង
ឃើញឈើមួយធំផង ចំនួនប៉ុនបីឱបតឹង ។
អាសាញ់ព្យូរបាយហើយ ឈរព្រងើយធ្វើមិនដឹង
ឪពុកប្រឹងសំលឹង ធ្វើទ្រមឹងទ្រមក់នៅ ។

ឪពុកហៅថានែ អាកុំបែរឈរសៅដៅ
អញកាប់ឈើនឹងទៅ ចាំទទួលទ្រីខំប្រឹង ។
ឪពុកប្រឹងតែកាប់ ប្រុងសំលាប់អាសាញ់ហ្នឹង
អាសាញ់ឈរសំលឹង ស្ទុះទៅទ្រឈើនោះណាំ ។
ឪពុកស្រែកថាវ៉ិយ ខំឃ្មាតខ្មីណាំអាវ៉ា
ឈើនេះធ្វើទូកក្តារ កុំអោយបែកបាក់ឡើយវ៉ិ ។
ឯឈើបាក់សង្កត់ អាសាញ់ស្រុតលិចក្នុងដី
ឪពុកស្រែកថាថ្វី ម្តេចក៏លិចបាត់ទៅហើយ ។
គិតស្រេចហើយយាត្រា ដើរម៉ីម្នាមកកន្តើយ
ថាវាស្លាប់ទៅហើយ កាលណានឹងរស់ឡើងវិញ ។
ដើរមកធ្វើព្រងើយ ភ្លេចបាយហើយពុំនឹកមិញ
ពុំត្រឡប់វិលវិញ ទៅយកបាយ់មកស៊ីឡើយ ។
គាត់ដើរចិត្តនឹកគិត ក្នុងគំនិតគាត់ជាត្រើយ
ពុំនឹកបាយទឹកឡើយ ចេះតែគិតក្នុងឥន្ទ្រិយ ។
កាលពីដើមមកនែ អញនឹងភ័យតែពីស៊ី
ឥឡូវគ្មានគ្នាគ្នី មកតាមស៊ីបំផ្លាញឡើយ ។
ពុំដឹងខ្លួននឹងស្លាប់ ពៀរសំលាប់គេនោះហើយ
គេពុំស្លាប់សោះឡើយ ពៀរនោះហើយស្លាប់ខ្លួនឯង ។
ដើរមករកលំនៅ វង្វេងផ្លូវដាច់សង្វែង
អត់បាយស្វិតពោះធេង ប្រាំពីរថ្ងៃក្ស័យជន្មា ។
និងថ្លែងហាក់ទៅវិញ ឯចៅសាញ់នៅកំព្រា
ដើបរួចក៏ម៉ីម្នា រកបិតាពុំឃើញឡើយ ។



ប្រឹងស្រែកដង្ហោយហៅ ថាឪពុកទៅណាហើយ
អញ្ជើញមកឪអើយ មកបរិភោគអាហារហោង ។
ស្រែកហៅពុំឮឆ្លើយ ទុក្ខពុំស្បើយឱរារង
ទើបវិលមកវិញផ្ទង យកអាហារបរិភោគក្តា ។
រួចហើយទើបក្រោកដើរ ទៅយកឈើលីលើស្មា
ទំហំបីឱបណា លីលើស្មាហើយដើរទៅ ។
វេរកផ្លូវទៀតណា ឯកអង្គាម្នាក់ឯងកូវ
ឥតគ្នាជាពីរនៅ គ្រាន់ដើរទៅរកមណ្ឌល ។
រីផ្លូវដែលដើរមក ឥឡូវរកក៏ពុំយល់
ចេះតែដើរវិលវល់ អំពល់ក្នុងព្រៃព្រឹក្សា ។

## បទបណ្តាកគតិ

ចៅសាញ់ដើរទៅ រកទីលំនៅអាត្មា
ពុំឃើញឡើងណាំ វង្វេងក្នុងព្រៃវក់វី ។
នឹងថ្លែងតទៅ ឯម្តាយនិត្យនៅផ្ទះខ្ចី
ចាំមើលផ្លូវប្តី ពុំឃើញបាត់ទាល់ល្ងាចណាំ ។
ចេះតែទន្ទឹង សញ្ចប់សញ្ជឹងខ្លោចផ្សា
ព្រួយចិន្តា ពុំបាននិន្ទ្រាតិចឡើយ ។
ឮមាន់រងាវ ស្មានថាប្តីហៅគិតឆ្លើយ
បើកទ្វារឡើយហើយ រកមើលពុំឃើញឡើយណាំ ។
ស្តាប់ជាក់ជាមាន់ ក្នុងចិត្តខ្នាញ់សោះសា
ថាឱអនិច្ចា អ្នកជាស្វាមីខ្ញុំនេះ ។

ក្ស័យឬយ៉ាងណា    បានជាម្ដាយបាត់ដល់ម្ល៉េះ
ថ្ងៃមិញយប់នេះ    ក៏ពុំឃើញមុខមាត់ ។
មើលផ្លូវបាត់ហើយ    នាងនៅព្រងើយស្ងៀមស្ងាត់
ហេតុត្បិតប្ដីបាត់    ស្ងៀមស្ងាត់រកស៊ីទៅណា៎ ។
នេះនឹងថ្លាថ្លែង    និទានចាយចែងចរចា
ទៅថៅសាញ់ណា៎    ឯការដើរតែក្នុងព្រៃ ។
ចេះតែដើរទៅ    ពុំដែលដឹងផ្លូវឡើយនៃ
ដើរត្រាច់ក្នុងព្រៃ    រកផ្ទះពុំឃើញឡើយណា៎ ។
ឃើញតែពួកសត្វ    ក្នុងចិត្តស្ងប់ស្ងាត់សោះសា
ថាឱអនិច្ចា    អញអើយកំព្រាម្នាក់ឯង ។
ឱសត្វទាំងឡាយ    នៅសុខសប្បាយឥតក្រែង
អញអើយតែឯង    ហៅមហាចំបែងពុំស្បើយ ។
មិនដូចសព្វផង    ច្រើនក្រៃកន្លងជាត្រើយ
មូលនឹងគ្នាហើយ    ដើរទៅឯណាច្រើនក្រៃ ។
អញដើរតែឯង    គិតគ្រប់ស្ងប់ស្ងែងណាស់ខ្មី
ក្រែងសត្វអ្វីៗ    វាមកយាយីពាធ ។
រីឯដើមឈើ    ដែលអញលីលើស្មាណា៎
ទើសនឹងព្រឹក្សា    ក៏បាក់បែកវាលស្រឡះ ។
ដើរមកយូរឆ្ងាយ    ដល់ពីរខែប្លាយកន្លះ
ខំដើររកផ្ទះ    ពុំឃើញពុំយល់សោះសា ។
រីឯថៅសាញ់    ក្នុងចិត្តគ្នាន់ខ្នាញ់ណាស់ណា
ទោះទាំងភោគនា    នោះក៏ពុំបានបរិភោគ ។



ដើរតែក្នុងព្រៃ    សង្រេងសង្រែងទុក្ខសោក
ខំតែដើរឈ្មោក    ពុំឃើញចេះតែយាត្រា ។
រីដំណើរនេះ    យើងនឹងទុកស្លេះសិនណា៎
បង្ហានទុកជា    ដើរតែក្នុងព្រៃឯកអង្គ ។
នេះនឹងស្រដី    ទៅឯបុរីរាគរុង
មួយនាមឧត្តុង្គ    នគរព្រះបាទព្រហ្មទត្ត ។
ព្រះអង្គសោយរាជ្យ    មែនមានអំណាចពេកក្កាត់
គ្រងអស់រាស្ត្ររដ្ឋ    នៅក្នុងនគរភូមិស្រុក ។
ស្ដេចសុខសប្បាយ    អស់រាស្ត្រទាំងឥតទុក្ខ
ព្រះអង្គសឹងសុខ    ពុំដែលមានទុក្ខភ័យសោះ ។
មនុស្សផងច្រើនក្រៃ    សប្បាយសព្វថ្ងៃទាំងអស់
ទោះស្រីទោះប្រុស    ស្រួលស្រស់ក្សេមក្សាន្តចិន្តា ។
ខ្លះលក់ទំនិញ    អ្នកខ្លះសោតទិញគ្នាណា៎
ខ្លះកាត់ថ្លៃថា    បីទៀតសាមសិបល្មមថ្លៃ ។
លក់ដូរទៅមក    រអែករអោកសព្វថ្ងៃ
ពុំដែលមានភ័យ    ធ្លាប់សុខរៀងៗមកណា៎ ។
មានកាលមួយថ្ងៃ    យក្សមួយកាចក្រៃសោះសា
ចិត្តវាមោហា    វានឹងមរណាមិនខាន ។
យក្សនោះឯងណា៎    ចិត្តវាហានក្លាក្នុងប្រាណ
ចង់ស៊ីក្សក្សាន្ត    មិនដឹងខ្លួនស្លាប់ឡើយហោង ។
ទើបយក្សមោហា    ប្រាយប្រាប់ក្សត្រាជាម្ដង
អោយរកមនុស្សផង    មកដាក់ស្នួយអោយអញផ្លាក់ ។

បើពុំព្រមដាក់　សួយអោយអញជាក់មផ្សែត
នោះទាំងមហាក្សត្រ　អញស៊ីពុំលែងឡើយណាំ ។
យក្សប្រាយប្រាប់ហើយ　វិលវិញព្រងើយសោះសា
ដល់ស្ថានហើយណា　ម្ទីម្នាចូលទៅវៃៗ ។
កាលក្រោយយក្សទៅ　ព្រះបាទចមចៅស្តេចភ័យ
ទាំងរាស្ត្រមន្ត្រី　ប៉ុន្មានសឹងភ័យពុំស្បើយ ។
ខ្លះរត់ម្ទីម្នា　ប្រាប់គ្នីគ្នាជាត្រើយ
ថានៃវុីអើយ　កុំទៅណាឆ្ងាយឡើយណាំ ។
អស់មនុស្សទាំងឡាយ　ភិតភ័យប្រញាយសោះសា
ថាឱអនិច្ចា　ជាហេតុប្រការកអ្វី ។
នាំគ្នាកើតទុក្ខ　ពុំបានទិញលក់ឡើយនៃ
ចេះតែភិតភ័យ　ខ្លាចក្ស័យជីវិតរាល់គ្នា ។
ស្តេចត្រាស់អោយហៅ　អាធុងចូលទៅម្ទីម្នា
ត្រាស់បន្ទូលថា　អាធុងអញចង់ប្រើឯង ។
ទៅថ្លែងប្រាប់យក្ស　ថាអញព្រមដាក់សួយស្ដែង
ចាំធ្វើកន្លែង　ប្រាំពីរថ្ងៃទៀតសិនហោង ។
ត្បិតឯងជា　អ្នកប្រាជ្ញាជាក់ជាម្ដង
ឯងប្រាប់វាផង　ដោយនូវដំណើរអញថា ។
អាធុងចងចាំ　នូវព្រះបណ្ដាំរាជា
ទើបបង្គំលា　យាត្រាវិលវិញទៅថ្កាន ។
ដល់មកផ្ទះហើយ　ជាទុក្ខពុំស្បើយក្នុងប្រាណ
ទើបរិះគិតធ្យាន　អញយកប្រាជ្ញាបទណា ។



គិតស្រេចហើយនៃ　ចុះដើរទៅវៃសោះសា
រិះរកប្រាជ្ញា　ដោយនូវឧបាយកលហោង ។
ដើរទៅហើយណា　ដល់ស្ថានយក្សាដូចប៉ង
ចរចូលទៅផ្គង　ដល់ទីលំនៅយក្សស្រេច ។
ទើបយក្សសួរថា　ឯងមកមានការដូចម្ដេច
ដំណើរសេចក្រេច　ដូចម្ដេចប្រាប់អញអោយហើយ ។
អាធុងឆ្លើយថា　បពិត្របិតាខ្ញុំអើយ
អ្នកឯងជាត្រើយ　ខ្ញុំសូមជាឪពុកខ្ញុំ ។
ឥឡូវនេះនៃ　ព្រះមហាក្សត្រថ្លៃឧត្ដម
ព្រះអង្គប្រើខ្ញុំ　អោយមកជំរាបលោកឪ ។
ព្រះអង្គព្រមដាក់　សួយអោយជៀងជាក់ហើយកូវ
ប៉ុន្តែអោយឪ　ចាំប្រាំពីរថ្ងៃទៀតហោង ។
ចាំធ្វើសាលា　រួចស្រេចហើយណាជាម្ដង
សូមឪទៅហោង　ព្រះអង្គស្ដេចដាក់សួយអោយ ។
យក្សស្តាប់ពាក្យពេចន៍　អស់អាចសេចក្រេចច្នេះហើយ
អរឯងពុំស្បើយ　ហេតុពៀរវេលាអាត្មា ។
និងក្ស័យជីវិត　ខ្លួនឯងពុំគិតឡើយណាំ
ហេតុចិត្តមោហា　ដែលវាប្រមាថស្ដេចហោង ។
ទើបយក្សមោហា　ប្រាប់អាធុងថាជាម្ដង
អញព្រមដែរហោង　ឯងវិលទៅទូលស្ដេចចុះ ។
យក្សប្រាប់ស្រេចហើយ　គិតពុំលង់ឡើយកាលនោះ
ទើបអាធុងស្ពោះ　លាយក្សមកផ្ទះអាត្មា ។

| | |
|---|---|
| មកដល់ផ្ទះហើយ | ពិតពុំលង់ឡើយមីម្នា |
| ចរចុះយាត្រា | ទៅទូលព្រះមហាក្សត្រថ្លៃ ។ |
| ទៅដល់ហើយណាំ | ក្រាបទូលក្សត្រាជៀសជ័យ |
| ឥឡូវនេះនៃ | យក្សនោះវាព្រមហើយណា ។ |
| ស្តេចទ្រង់ជ្រាបហើយ | ពិតពុំលង់ឡើយក្សត្រា |
| ប្រាប់អស់សេនា | អោយរៀបអស់គ្រឿងប្រដាប់ ។ |
| នឹងអស់សាលា | ប្រាំពីរថ្ងៃណាអោយឆាប់ |
| អោយបានប្រញាប់ | នៅក្នុងកំណត់ប៉ុណ្ណោះ ។ |

កាលនោះព្រះបាទក្សត្រាបង្គាប់សេនាស្រេចហើយក៏យាងចូលទៅ ។ សេនាថយចេញទៅក្រៅទៅ ។ សេនាថយចេញទៅក្រៅទើបបង្គាប់ទៅអស់ទាំងភ្នាក់ងារទាំងឡាយ ។ អោយនាំឈើមូលមកថ្វាយត្បិតព្រះនោមឆាយព្រះអង្គអោយធ្វើសាលា ។

ភ្នាក់ងារស្តាប់ព្រះអាជ្ញា ហៅគ្នាមីម្នានាំឈើចូលមកឆាប់វៃ ។ ទើបរៀបប្រដាប់ទីទៃនាំឈើពីព្រៃរំពេចដូចព្រះបង្គាប់ ។ ខ្លះតឿនគ្នាថាប្រញាប់រៀបធ្វើអោយឆាប់អោយរួចដូចព្រះអាជ្ញា ។ ខំធ្វើប្រញាប់មនីម្នាលុះរួចសាលា ទើបចូលទៅក្រាបទូលហោង ។ ព្រះបាទព្រហ្មទត្តច្បាស់ច្បងទ្រង់ជ្រាបហើយហោងអោយហៅអាធុងចូលទៅ ។អាមាត្យរត់ដល់លំនៅអាធុងហើយហៅប្រាប់ទៅដូចព្រះឱង្ការ ។ ទ្រង់មានព្រះបន្ទូលថា អោយទៅមីម្នាឥឡូវដូចព្រះប្រញប្តិ ។ អាធុងនោះបានស្តែងស្តាប់ព្រះបន្ទូលប្រាប់ប្រញាប់រៀបអង្គអាត្មា ។ ចរចុះដើរទៅមីម្នាដល់ចុងរោងណាក្រាបថ្វាយបង្គំក្សត្រថ្លៃ ។ ទ្រង់ទតទ្រង់ត្រេកអរក្រៃ ទ្រង់បន្ទូលវៃថាឯងរកមនុស្សដាក់ស្នួយ ។ មនុស្សដែលមានទោសដល់មួយជីវិតកុំព្រួយដាក់ស្នួយថ្ងៃម្នាក់ហោងអាធុងក្រាបជាម្តងយកមនុស្សទោសផង ដាក់ស្នួយដូចព្រះបង្គាប់ ។ រួចហើយថយចេញប្រញាប់វិលវិងក្រឡាប់ដើរមកផ្ទះទាំងភ័យ



ភ្ញាក់ ? នឹងថ្លែងតតែងជៀងជាក់ទៀតទោងយក្សអប្បលក្ខណ៍ចោរកាចពេកក្រៃ ។ លុះដល់គំរប់គ្រប់ថ្ងៃ យក្សចោរចង្រៃមោហាក្លាកាចអប្រិយ ។ មកដល់សាលាហើយខ្នចូលឆាប់មីម្នាហែកស៊ីសាច់មនុស្សនោះទៅ ។ តែសព្វៗថ្ងៃនិត្យនៅ លុះបានដល់ទៅប្រាំថ្ងៃនោះឯងហោងណា ។ យើងស្លេះពុំទាន់ចរចានេះនឹងថ្លែងថា ទោងចៅសាញ់ជាត្រើយ ។ មកដល់ចុងស្រុកនោះហើយព្រួយប្រាណ ពុំស្បើយបីខែប្រាកដជាម្តង ។ អត់បាយដើរតែឯងផងបីខែហើយហោង ដើរតែក្នុងព្រៃជាក់ស្តែង ។

គន់គិតក្នុងចិត្តខ្លួនឯងថា អ្នកណាតែងសាលាដាក់ទាននៅនេះ ។ ហើយនឹកថាអភ័ព្វអញអេះបានសាលានេះគ្រាន់ឈប់អាស្រ័យជាម្តង ។ លុះដើរដល់សាលាហោងទំលាក់ឈើផ្តងក៏ឮសន្ធឹកខ្លាំងក្រៃ ។ នឹងថ្លែងទៅអាធុងនៃឮស័ព្ទលាន់ក្រៃ នឹកថាសន្ធឹកស័ព្ទអ្វី ។ គិតស្រេចទើបចុះដី ដើរទៅឆាប់ខ្មី ក៏ឃើញអាសាញ់ក្រអេះ ។ ហើយនឹកថាអាចោរនេះមកពីណាអេះ គួរអញដណ្តឹងសួរវា ។ គិតស្រេចហើយចរយាត្រាទៅដល់សាលា ក៏ឃើញនូវឈើនោះហោង ។ ឃើញធំពន់ពេកកន្លងគួរខ្លាចជាម្តងគួរយកគេជាគ្នីអញ ។ គិតស្រេចឡើងទៅឃ្មាតខ្មាញ់ហៅថាសំឡាញ់ឯងមកពីស្ថានណា ។ អាសាញ់ឮហើយឆ្លើយថាដោយនូវកិច្ចាអាត្មាក៏ឃ្លានបាយផង ។ វីឯខ្លួនអញនេះហោងពុំដឹងស្រុកផង ដើរតែក្នុងព្រៃទេណា ។បីខែលំបាកអាត្មា ទោះទាំងភោជនានោះ ក៏ពុំបានបរិភោគ ។ ពុំដឹងទីស្ថានផ្លូវច្រកចេះតែដើរមកទើបឃើញសាលានេះណា ។ នឿយណាយចូលឈប់សិនវ៉ា នៅក្នុងសាលាសំរាកកំលាំងសិនហោង ។ ចាំតែបាត់ក្តៅរោយខ្នង នឹងយាត្រាផ្តងទៅរកលំនៅជាត្រើយ ។ វីឯអាធុងឆ្លាស់ឆ្លើយថា សំលាញ់អើយចូលឯងទៅនៅនឹងអញ ។ នោះទាំងបាយទឹកនោះមិញធានានូវអញនឹងចិញ្ចឹមឯងជាម្តង ។ អាសាញ់ឆ្លាស់ឆ្លើយវិងស្នងថា អញនេះហោងបរិភោគអាហារច្រើនក្រៃ ។ អាធុងថា អញសង្ស័យឯងស៊ីសព្វថ្ងៃមួយថ្ងៃតើអស់ប៉ុន្មាន ។ អាសាញ់ឆ្លាស់ឆ្លើយវិងថ្កាន អញស៊ីប្រមាណតិចទេមួយថ្ងៃបីថាំង ។ អង្ករសម្រិតសម្រាំងមួយថ្ងៃបីថាំងនោះឯង ទើបបានគ្រាន់អញ ។ អាធុងឆ្លើយថាសំឡាញ់ធានានូវអញចិញ្ចឹមរក្សាឯងហោង ។ អាសាញ់ព្រមតាមជាម្តងហើយចុះ

ទៅផ្តង់ជាមួយនឹងអាធុងណា ។ លើកឈើលីទៅសោះសាហើយចរយាត្រាម៉ីម្នាទៅផ្ទះ
អាធុង ។ ដល់ហើយទម្លាក់ឮក្តុងមុខផ្ទះអាធុង កុំបែកខ្ទាត់ខ្ចាយពីគ្នា ។ អាធុងប្រាប់ទៅ
ភរិយានូវអស់មនុស្សម្នា អោយរកបាយបីខ្ទះត្នោត អស់ខ្ញុំដណ្តាំបាយសោតបានបីខ្ទះ
ត្នោតស្រេច អោយអាសាញ់បរិភោគ ។ សម្លស្លបន្លែឃ្លោក អាសាញ់បរិភោគបីខ្ទះក៏អស់
ទៅហោង ។ វីអស់មនុស្សម្នានោះផង សឹងស្ញែងកន្លងព្រោះបរិភោគច្រើនក្រៃ ។ ព្រឹក
ល្ងាចលុះបានពីរថ្ងៃ កម្លាំងច្រើនក្រៃ ដូចកាលពីដើមជៀងជាក់ ។ នឹងថ្លែងចែងទៅឯ
យក្សកំណាត់វាជាក់ជាក្បីយក្នុងថ្ងៃនោះនែ ។ រសៀលព្រះសុរិយាវេរីសាញ់នែបរិភោគ
បាយរួចហើយហោង ។ ទើបអាធុងប្រាប់ដើមទងអាសាញ់ជាម្តងអញប្រើទៅទារប្រាក់ ។
ត្បិតឪអញគាត់ជំពាក់ ឯងទៅយកប្រាក់មកគ្រាន់ទិញស្រូវស៊ី ។ បន្តិចគាត់មកឯទីសាលា
នោណានោះខ្មឹងឯងទៅចាំគាត់មុនណា ។ អាសាញ់បានស្តាប់បញ្ជា ទើបចរយាត្រាទៅឯ
សាលានោះនែ ។ លុះថ្ងៃប៉ប្រះមាត់ព្រៃយក្សចោរចង្រៃហោះមកចាប់មនុស្សភោក្តា ។
យក្សយង់មកដល់សាលាទើបឆាប់ម្ពីម្នាដល់ទៅមាត់ទ្វារនោះហើយ ។ អាសាញ់ផ្សូរផ្សង
ឡើយថា នែឪអើយ អាធុងវាអោយទារប្រាក់ ។ យក្សស្តាប់ពាក្យអាសាញ់ជាក់ស្រដីទារ
ប្រាក់ យក្សភ្ញាក់ភ័ន្តភាំងស្មារតី ។ យក្សថាជំពាក់ប្រាក់អ្វីអញពុំក្តី ជំពាក់ប្រាក់កាស
នរណា ។ អាសាញ់ឆ្លាស់ឆ្លើយទៅថា អាធុងចរចាថាឪជំពាក់ជាម្តង ។ ប្រាក់មួយកន្តាំង
នោះហោងហេតុនោះជាម្តង ទើបវាប្រើខ្ញុំមកទារ ។ យក្សស្តាប់ពុំចរចាស្ទុះទៅប្រវា
ចាប់នូវអាសាញ់ខ្ទាប់ហើយច្របាច់កមិនលែងឡើយ ទើបអាសាញ់ឆ្លើយថា ឪលែងអញ
ចេញវ៉ា ។ លេងអ្វីដៃធ្ងន់ម្លេះណា លែងអញឆាប់វ៉ាលេងម្តេចដៃធ្ងន់អម្បាយ ។ អោយ
លែងមិនលែងគេងាយ ច្របាច់ស្ទើរធ្លាយបំពង់កគេជាម្តង ។ អាសាញ់ប្រាប់ទៅច្រើន
ដងមិនលែងឡើយហោងថា នែឪលែងអញចេញ ។ បន្តិចត្រូវកំភ្លៀងមិញមិនលែងក
ចេញអញទះកំភ្លៀងឥឡូវ ។ កុំលេងដៃធ្ងន់ពេកគួរ ទើបថានែឪលែងអញអោយឆាប់ម្ពី
ម្នា ។ យក្សស្តាប់ពុំលែងឡើយណា ខំតែប្រវាកាច់អោយបាក់កជាម្តង ។ អាសាញ់គ្រោធ
ក្រៃកន្លងអត់ពុំបានហោង ក៏ទះកំភ្លៀងយក្សនោះស្លាប់ទៅប្រាកដជាក់អាសាញ់លោត



ធាក់ថែមត្រូវមួយចុងជើងទៀត ។ ទើបអាសាញ់វាទៅឆ្លៀតស្តាប់ដង្ហើមទៀត ក៏ផុត
ដង្ហើមជាត្រើយ ។ ខ្លួនក៏ត្រជាក់អស់ហើយ ទើបគិតទៅហើយណា ។ គិតស្រេចចុះពី
សាលាដល់ដីម៉ីម្នាយាត្រាទៅទាំងអធ្រាត ដើរទៅខំស្រូតឱ្យឃ្មាតទាំងយប់អធ្រាត្របាន
ដល់ផ្ទះអាធុង ហើយស្រែកហៅពីក្រៅថា វើយអឺអាធុងអើយ បើកទ្វារអោយអញទៅ
ផង ។ អញវិលមកវិញហើយហោងបើកទ្វារអោយផង ត្បិតមូសវាខាំអញណាស់ ។
ហៅពីរបីដងស្រឡះអាធុងពុំច្បាស់ភ្ញាក់ឡើងខំផ្ទៀងឱ្យឃ្មាត ។ នរណាហៅទាំងអធ្រាត្រ
មានការអ្វីទៀត ក៏ហៅទាំងរាត្រីណា ។ អាសាញ់ឮហើយឆ្លើយថាអញហៅទេណា បើក
ទ្វារអោយអញទៅផង ។ អាធុងស្តាប់ជាក់ហើយហោងទើបគិតកន្លងថា អញប្រើទៅ
អោយស្លាប់ ។ ម្តេចឡើយវាប្រែក្រឡាប់ទៅហើយមិនស្លាប់ ក៏រស់មកវិញជាម្តង ។ ឬ
មួយខ្មោចអាសាញ់លង ឬមួយម្តេចម្តងក៏យកអង្ករបាយទៅ ។ អាសាញ់ចេះតែស្រែក
ហៅនៅឯខាងក្រៅមូសខាំទះស្ទើររួយដៃ ។ អាធុងបាចអង្ករវៃទាំងអំបិលនៃក៏អស់មួយ
ពាងទៅហើយអាសាញ់មិនលែងហៅឡើយចេះតែហៅហើយច្រើនដងច្រើនគ្រាចែៗ ។
ឆ្កែព្រូសលូៗខ្សែៗ អាសាញ់ថាឆ្កែអញទេឯងព្រូសអញថ្វី ។ អាធុងបានឮសំដីអាសាញ់
ហើយនៃ ក៏ជឿថាជារស់មែន ។ បើកទ្វារម៉ីម្នាមែនទែនចុះអនឯនកាន់ចន្លុះបំភ្លឺហើយ ។
ឃើញអាសាញ់ជាក់ជាត្រើយអះឯងឥតស្បើយនឹងថាអញបានជាធំ ។ រួចទើបបើករបង
“រួចហើយក៏សុំអាសាញ់អោយឡើងគ្រិះហា” ។ ទើបសួរទៅអាសាញ់ថាដូចម្តេចឬ អា
សាញ់ឯងទៅទារប្រាក់នោះ ។ អាសាញ់ប្រាយប្រាប់ទៅស្មេះថាឪឯងនោះម្តេចក៏កាចក្រៃ
កន្លង ។ អញប្រាប់ទៅគាត់ច្រើនដង ថាពីឯហោងអោយមកទារប្រាក់នោះណា ។ គាត់
ស្តាប់ហើយគាត់ឆ្លើយថាដោយនូវវាចាសំឡេងគាត់នោះធំ ៗ ។ គាត់ថាឯអញនេះពុំ
ដែលធ្លាប់ទៅជំពាក់ប្រាក់របស់នរណា ។ ថាហើយស្ទុះមកប្រវាចាប់កអញណា ច្របាច់
ស្ទើរតែនឹងបែក ។ បំពង់កស្ទើររហែកអញប្រឹងតែស្រែកគាត់ប្រឹង ។ អញក្រេវក្រោធ
ក្រៃពេកពន់គាត់រិតដៃធ្ងន់ អញអត់ពុំបានឡើយណា ។ អញទះកំភ្លៀងដួលផ្ងារ នៅលើ
សាលា ក៏ស្លាប់តាយហោងទៅ ហើយ ។ អាធុងស្តាប់ជាក់ជាត្រើយអរឯកពេកហើយ

ទើបញ្ញោតទៅអាសាញ់ ។ ថានែអាឯងនឹងអញនេះជាសំឡាញ់នឹងគ្នាប្រក្រតីមកនែ ។ យក្សនោះរបស់ក្សត្រថ្លៃម្តេចក៏ហ៊ានក្រៃដល់វាយអោយវាមរណា ។ ណ្ហើយចុះបើច្នោះចូរអាទៅអូសយកសពនោះចោលចេញអោយបាត់ទៅ ។ កុំអាទុកវានៅក្នុងស្រុកនោះគួរ ក្រៃងគេដើរទៅឃើញណា ។ សឹមអញទៅទូលក្សត្រាអោយទ្រង់មេត្តាករុណាអត់ទោសអាម្តង ។ ទោះព្រមមិនព្រមក្តកហោងអញនឹងទូលស្នង ដោយកូនសេចក្តីនេះណា ។ អាសាញ់ស្តាប់ហើយយាត្រាទៅឯសាលាអូសខ្មោចយក្សាចោលទៅ ។ ទើបយាត្រាវិលវិញកូវដល់ផ្ទះដែលនៅ ឡើងទៅនិទ្រាហើយណា ។ លុះដល់រស្មីសុរិយារះឡើយកាលណា អាធុងភ្ញាភ្ញាក់ហើយហោង ។ លុបមុខរួចស្រេចជាម្តងទើបតែងខ្លួនផងស្រេចហើយចុះពីផ្ទះទៅ ។ ដើរដល់ទៅចុងរោងគ្រៅព្រះបាទចមចៅ ព្រះអង្គយាងចេញមកហោង ។ អាធុងក្រាបទូលជាក្តងបពិត្រព្រះច្បងតាមតែទ្រង់ព្រះមេត្តា ។រីឯក្រុងយក្សមោហានោះខ្ញុំករុណាបានវាយវាស្លាប់ទៅហើយ ។ ព្រះអង្គត្រាស់វិញជាត្រើយបើដូច្នោះហើយយកធ្វើជាចៅហ្វាចុះ ។ ព្រះអង្គប្រទានត្រាស្មោះទីចៅហ្វានោះមកអោយអាធុងហើយណា ។ អាធុងរៀបអស់ភ្ញភ្ញីផ្កាថ្វាយបង្គំងារទទួលត្រាតាំងជាម្តង ។ បរិបូណ៌សូវេចហើយហោងទើបវិលវិញផ្គងកាន់ផ្ទះអាត្មាវិញណា ។ ហើយប្រាប់ទៅអាសាញ់ថាព្រះមហាក្សត្រាព្រះអង្គពុំព្រមឡើយនែ ។ ដូច្នេះឯងវេះទៅព្រៃចាំយប់សិននែសឹមឯងវិលមកផ្ទះណា ។ អាសាញ់បានស្តាប់វាចាអាធុងហើយណាទើបយាត្រាទៅពួនព្រៃ ។ ពួនជិតរន្ធសត្វបក្សី សន្មតនាមនែហៅសត្វឥន្ទ្រីនោះណា ។ លុះដល់ព្រលប់សុរិយាវិលមកគេហារកបាយបរិភោគស្រេចហើយ ។ ចូលទៅនិទ្រាជាត្រើយ លុះថ្ងៃឡើងហើយយកបាយទៅស៊ីក្នុងព្រៃ ។ លុះទៅបាន៧ថ្ងៃឯបុត្រីព្រះព្រហ្មទត្តរាជា កើតក្តៅក្រហាយអង្គានៅវាំងពុំជាទ្រង់ចង់លីលាលេងព្រៃ ។ ព្រះគួនឹងសាញ់នៃគិតស្រេចស្រីថ្លៃ ទៅលាមាតាបិតា ។ ព្រះអង្គព្រមបើកហើយណា បង្គាប់សេនាអោយរៀបអស់ពលសេនីយ៍ ។ សេនាស្តាប់គម្រាស់ខ្មីថយចេញវៃៗ ទៅបង្គាប់អស់យោធា ។ ហើយរៀបព្រះរាជាថានូវរាជអស្សាទាហានពលផងសល់សែន ។ អាមាត្យជាអ្នកវៃក្លែនរូតរត់មែនខែនទៅប្រាប់



ទាហាន ឆាប់វៃ ។ ទាហានរៀបខ្លួនហើយនែ ខ្លះកាន់ទង់ជ័យខ្លះសោកកាន់លំពែងដាវ ។ អាមាត្យជាធំ ចូលទៅទូលព្រះចមចៅបពិត្ររួចហើយក្សត្រថ្លៃ ។ ព្រះអង្គទ្រង់ជ្រាបហើយនៃត្រាស់ទៅឆាប់វៃនឹងរាជបុត្រីពន្លក ។ នាងទៅចូរនាងឆាប់មកណាស្ងួនពន្លកសំឡាញ់នៃបិតាហោង ។ នាងស្តាប់ហើយនាងទូលស្នងដល់រសៀលហោងខ្ញុំម្ចាស់យាត្រាមកវិញ ។ទូលភ្លាម ទើបនាងយាងចេញពលទាហានមិញអញ្ជើញគង់រាជរថា ។ រីអស់ស្នំស្និទ្ធស្នេហាសឹងជិះរថា ខ្លះជិះរទេះទឹមគោ ។ ស្រេចហើយអស់ពលផងហ៊ោព្ទសត្វនោឡោលោកចេញទៅព្រៃជាម្តង ។ នេះនឹងថ្លាថ្លែងទៅត្រង់តទៅដល់អង្គចៅសាញ់និត្យនៅកំព្រា ។ ឃើញអស់ទាំងពលយោធាភ័យក្រៃមហិមា ក្រៃងតែគេលើកមកចាប់ ។ភ័យណាស់រត់ទៅប្រញាប់សម្ងំពួនផ្ទាប់រន្ធសត្វឥន្ទ្រីនោះអេះ ។ រីឯដំណើរន័យនេះ យើងនឹងឈប់ស្លេះនៅនេះពុំទាន់ស្រដី ។ នឹងថ្លែងឯរាជបក្សីដែលនៅក្នុងព្រៃមើលយល់ក្សត្រីសោកា ។ គង់លើព្រះរាជរថាហើរមកម្ទីម្ទាចុះឆាបយកនាងទៅហោង ។ រីឯស្នំស្និទ្ធពលផងយល់ដូច្នោះហោង ក៏ស្រែកប្រាប់ទៅសេនា ។ អើអស់លោកអ្នករាល់គ្នាហ្ន៎សត្វអ្វីណាឆាបរាជធីតាទៅហើយ ។ សេនាភិតភ័យពុំស្បើយ លើកគ្នាតាមហើយក៏ពុំទាន់សត្វនោះណា ។ ប្រឹងស្រែកប្រទេចផ្តាសាដោយនូវក្រោធាខ្លះ នាំគ្នាអង្គុយយំ ថាឱម្ចាស់ថ្លៃឧត្តមម្លេះសមយើងខ្ញុំនឹងក្ស័យជីវិតពុំខាន ត្បិតតែសត្វចោរសាមាន្យយកម្ចាស់កល្យាណ ទៅបរិភោគមិនលែងឡើយ ។ សេនាត្រឡប់មកវិញវិលរឹងជាត្រើយមកដល់ក្នុងវាំងរាជា ។ ស្តេចទតទៅយល់ហើយណា ទើបត្រាស់សួរថាម្តេចកូនពុំងាថ្លើមថ្លៃ ។ កូនអញនាងទៅលេងព្រៃសប្បាយ ឬ អ្វីហេតុដូចម្តេចឡើយឆាប់វិលមក ។ សេនាផងសឹងយំសោករអែករអោកនឹកថានឹងក្ស័យជីវិត ។ ទើបទូលទៅទាំងភ័យភិតខ្លាចក្ស័យជីវិតញ័រមាត់ញ័រកបំបាប់ ។ ទោះបីព្រះអង្គសម្លាប់នោះខ្ញុំសូមស្លាប់ទុរស់ជាខ្ញុំបាទា ។ រីនាងនាថធីតាត្រូវសត្វក្សាមួយនោះ ឈ្មោះសត្វឥន្ទ្រី ។ វាមកឆាបយកទៅស៊ី ខ្ញុំនាំគ្នាលើកតាមទៅមិនទាន់វា ។ ព្រះអង្គទ្រង់ស្តាប់វាចាញ័រព្រះអង្គាសោកស្តាយព្រះរាជបុត្រី ។ ទើបត្រាស់ដណ្តឹងទៅខ្មីថា ព្រឹកឡើងវៃឯងទៅប៉ាវគងម្ទីម្ទា ។ រកអ្នកណាមានវិទ្ធា

ទៅយកធីតាអញនោះបានមកវិញ ។ អញនឹងអភិសេកជាត្រើយ អោយសោយរាជ្យ ហើយកូនអញអោយជាភរិយា ។ លុះព្រឹកព្រាងព្រះសុរិយា អស់ទាំងសេនាចាត់មនុស្ស អោយចាំវគងផង ។ ស្រែកដូចបង្គាប់ជាម្តងរៀងៗ ទៅហោងពុំមាននរណាឆ្លើយថា ។ នឹងស្លេះទុកទៅសិនណាយើងនឹងចរចាទៅអាសាញ់នោះហោង ។ ហៀបនឹងត្រឡប់ជាម្តងទើបយាត្រាផ្តងមករកលំនៅវិញណា ។ ទើបអាធុងសួរទៅថា អាសាញ់កាលគ្រាឯងទៅបានឃើញឬអ្វី ។នាងនាថដែលសត្វឥន្ទ្រីឆាបយកទៅស៊ីឯងបានឃើញទេអាសាញ់ ។ អាសាញ់ឆ្លាស់ឆ្លើយទៅវិញ វាឆាបថ្ងៃមិញចូលរន្ធត្រង់មុខអញឯអាធុងសួរសាកឥតក្រែង បើដូច្នោះឯងទៅយកបាន ឬពុំបាន ។ អាសាញ់ឆ្លាស់ឆ្លើយទៅថ្កាន អញទៅយកបាន អញបានចំណាំរន្ធវា ។ អាធុងឆ្លាស់ឆ្លើយទៅថាបើដូច្នោះណាស្អែកនាំអញទៅយកនៃ ។ លុះព្រឹកព្រះសុរិយាទ័យអាធុងឆាប់វៃ ទៅទូលព្រះមហាក្សត្រា ។ ថាផានាខ្ញុំព្រះករុណាទៅយកធីតាមកថ្វាយព្រះមហាក្សត្រថ្លៃ ។ ព្រះអង្គទ្រង់ជ្រាបហើយនៃទ្រង់ត្រាស់ថា ហៃអាធុងបើឯងទៅយក ។ នាងនាថធីតាពន្លកកូនអញបានមកអញអោយសោយរាជ្យហោង ។ រីឯកូនអញនោះជាម្តងអញអោយឯងផងជាក់ជាភរិយាឯងប្រាកដលែងតែបានដូចជាទាំងរាស្ត្រប្រជាក៏អោយឯងគ្រងប្រាកដ ។ អាធុងស្តាប់ហើយអរក្តាត់បង្គំលាថ្វាត់មកផ្ទះអាត្មាវិញហោង ។ មកដល់លំនៅដូចបំងទើបប្រាប់ទៅផ្តងថា ហៃអាសាញ់ចូរបា ។ នាំអញទៅយកធីតា បើបានដូចថា ក្សត្រាព្រះអង្គលែងទោស ។ ដែលអាសម្លាប់យក្សនោះព្រះអង្គត្រាស់ផ្តោះថាអោយអាឯងទៅយក ។បើបាននាងនាថនោះមកព្រះអង្គពុំយកទោសដែលឯងវាយយក្សស្លាប់ ។ ប្រាប់ស្រេចរករៀបប្រដាប់សង្វែកសម្រាប់ប្រដាប់ទ្របាទកញ្ជើ ។ មានខ្សែដាក់យោងពីលើបង្ហូតកញ្ជើ ដាក់ទៅក្នុងរណ្តៅណាំ ។ រៀបស្រេចទើបចរយាត្រា លើកពលសេនាទៅក្នុងព្រឹក្សានោះនៃ ។ ដល់ទៅដល់មាត់រន្ធបក្សីទើបប្រាប់ទៅខ្មីថា រ៉ឺអាធុងនេះហើយ ។អាធ៉ុងស្តាប់ជាក់ជាត្រើយ រៀបសង្វែកហើយចងខ្សែដាក់កញ្ជើទៅ ។



## បទព្រហ្មគីតិ

រីឯរាជបក្សី    វាឆាបខ្មីនាងយកទៅ
ជូនឈ្មោល    វាមិននៅវាពុំទាន់បរិភោគក្តា ។
ក្នុងចិត្តរាជបក្សី    វាចាំប្តីវានោះណា
វាពុំទាន់ភោក្តា    ដ្បិតអាហារត្រកាលក្តាត់ ។
មិនតីជាសាច់អ្វី    គឺសាច់ស្រីជាតិជាក្សត្រ
ប្តីអញម្តេចក៏បាត់    គាត់មិនទាន់ឃើញមកខ្មី ។
អាសាញ់ចុះទៅដល់    ក្នុងមណ្ឌលរាជបក្សី
ភ្អែកគយគន់រំពៃ    យល់បក្សីនៅនោះណា ។
រីឯរាជបក្សី    ស្មានជាប្តីនៃអាត្មា
ទទួលឆាប់រួសរ៉ា    ហើយប្រាប់ថាខ្ញុំនៅព្រៃ ។
ប្រទះនឹងកូនស្តេច    យាត្រាត្រេចមកលេងព្រៃ
ខ្ញុំស្ទុះទៅឃ្មាតខ្មី    ឆាបក្សត្រីយកមកណា ។
ខ្ញុំទុកចាំអ្នកឯង    មកពីស្វែងរកភោជនា
ខ្ញុំមិនទាន់ភោក្តា    ចាំតែអ្នកឯងមកទេ ។
អាសាញ់ស្តាប់ហើយណា    ទើបប្រាប់ថាមើលមេៗ
ហាងស្លាប់មិនលែងទេ    ថានៃមីស្លាប់ចោលប្តី ។
បក្សីសោតស្តាប់ជាក់    ទើបភ្ញាភ្ញាក់ខ្លួនថាយី
មិនមែនប្តីទេរ៉ឺ    នេះជាក់ជាមនុស្សទេណា ។
ជាភ័ព្វអញពេកក្រៃ    អ្នកដទៃគេសទ្ធា
ដាក់មនុស្សមកទៀតណា    ជាអាហារអញឆ្ងាញ់ក្រៃ ។

គិតស្រេចស្ទុះទៅនាប់ ចៅសាញ់ចាប់បានជើងដៃ
កន្ត្រាក់មកនាប់វៃ ហើយក៏កាច់បំបាក់ទៅ ។
ចៅសាញ់ចុះទៅដល់ នាងនិមលរូបឥតសៅ
បែរបើកភ្នែកមើលទៅ ឃើញនាងនៅអង្គឯការ ។
ព្រះភក្ត្រក្សត្រីថ្លៃ ត្រៀមក្រំក្រៃឥតឧបមា
និងដល់ព្រះមាតា ព្រះបិតានៅឯនាយ ។
ចៅសាញ់រំពឹងយល់ នាងនិមលមិនសប្បាយ
ទើបមានពាក្យអភិប្រាយ លោមកំអោយនាងភយា ។
ថាហៃប្អូនពន្លក បងនេះមកយកប្អូនភ្វា
ទៅថ្វាយព្រះបិតា ព្រះមាតាប្អូនឯនាយ ។
ចូរប្អូនមាសកល្យាណ នាងកំសាន្តអោយសប្បាយ
បងយកប្អូនទៅថ្វាយ ចូរនាងទៅនឹងបងរ៉ា ។
នាងស្តាប់ហើយត្រេកអរ មានអំណរឥតឧបមា
ចង់ជួបនឹងបិតាចិត្ត ស្នេហាចៅសាញ់ពិត ។
នាងឆ្លើយដោយទំនងចិត្ត នាងប៉ងយកជាមិត្ត
នាងនាថរំពឹងគិត តែក្នុងចិត្តនាងនាថនៅ ។
នាងថាឱអ្នកអើយ អ្នកឯងហើយជាក់ជាគូ
នឹងខ្ញុំមកលង់យូរ ជាគូរព្រេងនឹងគ្នាហើយ ។
ទើបបានអ្នកមកជួយ ខ្ញុំមិនអោយដល់ស្លាប់ឡើយ
រួចពីសត្រូវហើយ យកខ្ញុំទៅនគរវា ។
នាងថាឱអ្នកថ្លៃ មានគុណក្រៃនឹឥតគណនា
ឥតអ្វីនឹងឧបមា ប្រៀបនឹងគុណអ្នកនេះបាន ។



ថាបើយើងទៅដល់ ទីមណ្ឌលរាជស្ថាន
បានជួបនឹងក្សត្រក្សាន្ត ឯធនធានមិនខ្វះអ្វី ។
កុំថាទ្រព្យទាបនោះ ទោះទ្រព្យខ្ពស់ប៉ុន្មានក្តី
ប្រាថ្នាចង់បានអ្វី តាមតែអ្នកប្រាថ្នាយក ។
ចៅសាញ់ឆ្លាស់ឆ្លើយទៅ ថាហៃពៅស្រស់ពន្លក
ខ្លួនបងប្រាថ្នាមក យកប្អូនទៅថ្វាយបិតា ។
មាតានាងទន្ទឹង ម្ល៉េះសមនឹងសោយសោកា
នោះទើបបងយាត្រា មកយកប្អូនទៅថ្វាយហោង ។
កុំអោយស្តេចបារម្ភ កើតទុក្ខធំក្រៃកន្លង
ព្រះទ័យក្សត្រច្បាស់ច្បង សោកអាល័យស្ងួនពុំងា ។
កុំប្អូនស្ងួនឧត្តម គិតបារម្ភបងឡើងណា៎
គិតទៅតែមាតា ព្រះបិតានាងឯនាយ ។
អោយបានស្តេចយល់ភក្ត្រ ប្អូនវលក្ខណ៍ស្រស់ឆោមឆាយ
អោយស្តេចបានសប្បាយ ក្នុងព្រះកាយសុខប្រសើរ ។
ទើបលើកនាងដាក់ទៅ អោយចិតនៅក្នុងកញ្ជើ
នាងថាមកពីលើ រួចហើយថាអ្នកចាំអ្វី ។
ចៅសាញ់ឆ្លើយទៅថា ហៃប្អូនភ្ងាមាសពិសី
នាងទៅមុនចុះខ្មី បងទៅក្រោយប្អូនប្រសើរ ។
នាងឆ្លើយថាទេអ្នក ក្រែងគេដាក់តែកញ្ជើ
មិនយកអ្នកហើយតើ បាននរណាគេមកយក ។
ចៅសាញ់ឆ្លាស់ឆ្លើយទៅ ថាហៃពៅស្រស់ពន្លក
ថាបើគេពុំយក បងនេះទៅក៏ហើយចុះ ។

អោយតែនាងបានទៅ　　កុំប្អូនពៅគិតវើរុះ
ឯបងជាកូនប្រុស　　យ៉ាងយូរណាស់ត្រឹមបីខែ ។
ថៅសាញ់រុញកញ្ជើ　　អ្នកឯលើចាប់ទាញខ្សែ
បានដល់មកលើឯ　　ថៅសាញ់នៅក្នុងរូងសត្វ ។
លើកនាងដាក់មកលើ　　ដោះកញ្ជើប្រញាប់ក្តាត់ ។
នាងនាថប្រាប់ទៅថ្វាត់　　ថានែអ្នកម្តេចដូច្នោះ ។
គ្នានៅក្នុងនោះនៃ　　ស្រាវមកអ៊ីទទេនោះ
ម្តេចមិនទម្លាក់ចុះយោង　　យកគ្នាមកប្រញាប់ ។
អាធុងឆ្លើយទៅថា　　យោងថ្វីអាចោរមុខងាប់
ទុកអោយវានៅស្លាប់　　ហើយស្រែកថាយើងឃ្មាតខ្មី ។
ចូរទៅអោយឆាប់រ៉ា　　រួសម៉្មីម្នាទៅចាំអ៊ី
ចូលគាល់ព្រះចក្រី　　អោយក្សត្រថ្លៃទ្រង់មេត្តា ។
អាសូរប្រោសប្រណី　　យើងទីទៃរាល់ៗគ្នា
ទោះនឹងចង់បានងារ　　ឬទ្រព្យអ៊ីក៏សឹងបាន ។
ទើបលើកពលវិលទៅ　　ដល់លំនៅរាជស្ថាន
ហើយនាំនាងកល្យាណ　　ចូលទៅគាល់ព្រះរាជា ។
ព្រះអង្គទតមកយល់　　នាងនិមលបុត្រពុំងា
ទ្រង់ត្រេកអរម៉្មីម្នា　　ឧបប្រវារធីតាថ្លៃ ។
ទ្រង់ព្រះកន្សែងសោក　　សែនអមោក្សពន់ពេកក្រៃ
ថាឱកូនមាសថ្លៃ　　យើងនឹងថាក្ស័យទៅហើយ ។
ឥឡូវកូនពន្លក　　នាងវិលបានមកស្រាកស្បើយ
បានជួបបិតាហើយ　　នូវមាតាស្ងួនមាសថ្លៃ ។



រីអស់ស្នំស្នេហា　　សឹងសោការាល់គ្នានៃ
ដោយចិត្តគិតអាល័យ　　យំស្មើរក្ស័យជន្មជីវិត ។
ឱមាសថ្លៃឧត្តម　　សព្វថ្ងៃខំព្រួយចិត្តគិត
ដល់ម្ចាស់ថ្លៃវរមិត្ត　　ទន់ស្រយុតអស់កាយា ។
ឥឡូវម្ចាស់មកដល់　　ខ្ញុំបានយល់ជាក់ហើយណា៎
សឹងបានស្បើយទុក្ខា　　បានបម្រើនៅផ្គត់ផ្គង់ ។
លុះស្បើយក្តីសោកា　　នាងយាត្រាទៅឯក្នុង
ប្រាសាទដែលនាងគង់　　នៅជាសុខសប្បាយក្រៃ ។
ឯព្រះបាទព្រហ្មទត្ត　　បន្ទូលថ្នាក់និងមន្ត្រី
អោយសង់រាជរោងជ័យ　　និងអភិសេកធីតាស្ងួន ។
អោយមានរបាំណា៎　　ដោយភាសាខ្មែរចិនយួន
រៀបអោយត្រូវនឹងក្បួន　　តាមរបៀបច្បាប់ព្រេងនៃ ។
សេនាស្តាប់បន្ទូល　　អរស្រុះស្រួលទទួលវៃ
ចរចេញមកទីទៃ　　ប្រាប់ភ្នាក់ងារការដោយខ្សែក ។
អោយរៀបរោងរបាំ　　តាមចំណាំអភិសេក
ថ្ងៃនេះនូវថ្ងៃស្អែក　　ហៅគ្នាមកធ្វើទៅហោង ។

## បទពំនោល

អស់ទាំងសេនាអឹងកង រៀបធ្វើរោងផងទាំងយប់ទាំងថ្ងៃសោះសា ។ យើងស្លេះពុំទាន់ចរចាថ្លែងតទៅណា៎ ឯថៅសាញ់វិញជាម្តង ។ នៅក្នុងរន្ធសត្វនោះហោងយូរក្រៃកន្លង ជិតដល់៣ខែហើយណា៎ ។ ទើបបានក្តៅដល់អាសនាសម្តេចឥន្ទ្រាធិរាជចមថៅក្សត្រក្សាន្ត ។ ទើបស្តេចបើកទិព្វចក្ខុញាណព្រះនេត្រថ្លើងថ្កាន ក៏ទតមកដល់ផែនដី ។

ទតសព្វភូមិភពបុរីពុំមានយល់អ្វីយល់តែចៅសាញ់ជាម្តុង ។ បុណ្យមានបានសោយរាជ្យហោងបារមីកន្លង និងបានជាម្តុងប្រាកដ ។ អាធុងនោះឯងកំណត់អាយុសន្មតនឹងអស់ជន្មានោះហោង ។ គិតស្រេចស្តេចហោះចុះផ្តងដល់ដី ជាម្តុងក៏ប្រែក្រឡាឆាប់ក្រៃ ។ រំពេចកើតជាពួរជ្រៃសំយុងទៅនៃក្នុងរណ្តៅនោះឯងណាំ ។ ចៅសាញ់ឃើញហើយប្រវាពួរជ្រៃនោះណាំក៏តោងឡើងមកដល់លើ ។ យប់ថ្ងៃរសៀលហើយតើ ទើបចរចេញដើរសំដៅផ្ទះអាធុងពិត ។ រីពួរជ្រៃនិម្មិតព្រះឥន្ទ្រប្រសិទ្ធិក៏បាត់ពុំឃើញឡើយហោង ។ ដើរមកដល់ទ្វាររបងផ្ទះអាធុងហោង ក៏ឡើងទៅលើគ្រឹះហា ។ ទើបប្រាប់ទៅអាធុងថា អាចធុងអើយអា អញឃ្លានបាយពេកណាស់នៃ ។ មនុស្សម្នាត្រៀបត្រាច្រើនក្រៃមន្ត្រីផងនៃក៏សឹងតែនៅពាសពេញកណ្តាលជំនុំនោះមិញ នាហ្មឺនគាល់ពេញមិនក្រែង មិនខ្លាចខ្លួនឡើយ ។ អាធុងក្រោធក្រៃពុំស្បើយ ស្តែងស្តាប់ជាក់ហើយទើបប្រាប់អស់ភ្នាក់ងារ ។ ថាចាំអ្វីមិនចាប់វាអស់ទាំងភ្នាក់ងារ ស្តាប់ហើយក៏ស្ទុះទៅចាប់ ។ ចៅសាញ់នោលឯងចងខ្ទាប់ទើបអាធុងប្រាប់ថា អោយនាំចេញទៅឆ្ងាយ ។ ប្រាប់ទៅភ្នាក់ងារទាំងឡាយអោយដាក់ខ្នោះ វាយហើយដាក់ច្រវាក់ឃ្នាងផង ។ ទំរាំតែព្រឹកស្អែកហោងចូរគ្នាយើងផងនាំវាយកទៅសម្លាប់ ។ កូនក្តួយនោះសោតបានចាប់ដាក់ច្រវាក់ខ្ទាប់ឃ្នាងខ្នោះ ជើងដៃផងណាំ ។ យើងស្លេះទុកនៅនេះណាំថ្លែងឯមេការប្រញាប់ធ្វើរោងនោះនៃ ។ ស្រេចបរិបូណ៌ប្រពៃនាគ្រានោះ នៃរៀបចងនូវគោមកែវផង ។ យើងស្លេះនៅនេះសិនហោងនិងថ្លែងៗ រំលងទៅចៅសាញ់វិញនៃ ។ លុះថ្ងៃបរិបូណ៌ប្រពៃនាំចេញទៅវៃរៀបគ្រឿងលំពែងជុំនៅ ។ ដង្ហែចៅសាញ់ចេញទៅបណ្តើរតាមផ្លូវអោយស្រែកអាក្រោសទៅហៅ ។ យើងស្លេះទៅនេះសិនហោងនិងថ្លែងទៅផ្តង ឯអគ្គអមរិន្ទ្រាថ្លៃ ។ កើតក្តៅក្រហាយពេកក្រៃនឹងក្នុងព្រះទ័យថាមានហេតុអ្វីច្នេះណាំ ។ គិតស្រេចសម្តេចឥន្ទ្រាបើកទិព្វចក្ខុទតយល់នូវរូបចៅសាញ់ ។ នឹងថាអ្នកនេះដែលអញជួយពីមុនមិញឥឡូវម្តេចត្រូវទោសទៀត ។ ច្នេះនឹងស្លាប់ចោលបង់សៀក អញជួយម្តងទៀតអោយរួចអំពីទោសា ។ គិតស្រេចហោះចុះមកណាទើបប្រែកាឡាជាតាចាស់មួយនាក់នៃ ។ កាន់សាយដៀវមួយ



ប្រពៃជំរង់ទៅពួត្រង់មុខចៅសាញ់នោះណាំ ។ ចៅសាញ់ក្រឡេកឃើញតាកាន់សាដៀវណាំ ក៏មានចិត្តត្រេកអរក្រៃ ។ ទើបអង្វរទៅថាហៃអ្នកពេជ្ឈឃាដថ្លៃចូរអ្នកអាណិតខ្ញុំវ៉ា ។

ខ្ញុំស្លាប់ឥឡូវហើយណាំសូមអ្នកមេត្តា បើកអោយខ្ញុំលេងសិនហោង ។ ខ្ញុំរត់ពុំរួចជាម្តុងខ្ញុំស្លាប់ហើយហោង អោយខ្ញុំលេងសិនទៅវ៉ា ពេជ្ឈឃាដស្តាប់នូវវាចាចៅសាញ់ហើយណាំក៏ព្រមបើកអោយលេងហោង ។ ទើបប្រាប់អស់ទាំងគ្នាផងបើដូច្នេះហោងចូរអស់ទាំងគ្នាមកស្រាយ ។ អោយវាលេងអោយសប្បាយអស់គ្នាទាំងឡាយឈរឃុំអោយជុំខ្លួនវា ។ ក្សិណនោះសម្តេចឥន្ទ្រា ចរចូលម្នីម្នាកាន់សាយដៀវមកផង ។ ចៅសាញ់ឃើញសាយដៀវហោងស្រដីហៅផ្តងថា នៃអ្នកតាមេត្តាអោយខ្ញុំខ្ចីសាយដៀវវ៉ា ខ្ញុំច្រៀងតិចណាំ អោយបានសប្បាយសិនហោង ។ តាចាស់ហុចសាយដៀវផ្តងចៅសាញ់ដេញលេងស្រេច ដេញជាសាច់ភ្លេងហើយច្រៀងនៅជើងវាំងជាត្រើយ តាំងចាប់ដើមឡើយពីកាលដែលវាយយក្សា ។ លុះទៅពួនក្នុងព្រៃណា ឃើញពលយោធាដង្ហែនាងទៅលេងព្រៃ ។ ខ្ញុំខ្លាចហើយខ្ញុំភិតភ័យរត់ទៅពួនវៃខាងរន្ធបក្សីនោះណាំ ។ បក្សីហើររកអាហារវា ឃើញធីតាវាឆាបយកនាងទៅហោង ។ លុះខ្ញុំទៅយកជាម្តុងនាងនាថនោះហោង បានរួចពីក្ស័យជីវិត ។ ហើយខ្ញុំនៅក្នុងរូងសត្វគេនាំនាងថ្វាត់ មកថ្វាយព្រះមហាក្សត្រថ្លៃ ។ នឹងថ្លែងទៅឯក្សត្រីនាងនាថនោះ នៃបានឮសំឡេងចៅសាញ់ ។ នាងនាថម្នីម្នាស្ទុះចេញមកឯក្រៅមិញបានឃើញសាញ់នោះណាំ ។ នាងនឹកតែក្នុងចិន្តាថាអ្នកនេះណាំដែលទៅយកអញឯងនៃ ។ គិតស្រេចសម្តេចក្សត្រីស្តេច ចូលទៅវៃក្រាបទូលព្រះវរបិតា ។ បពិត្រសូមទ្រង់មេត្តាខ្លួន ខ្ញុំនេះណាំបានរួចពីក្ស័យជីវ ។ ដោយអ្នកទោលនោះប្រណីសូមព្រះចក្រីបិតាទ្រង់ប្រោសខ្ញុំផង ។ គាត់ទៅយកខ្ញុំជាម្តុង រីអាធុងហោងនៅតែឯលើទេណាំ ។ ព្រះអង្គជ្រាបហើយក្សត្រាត្រាស់ ប្រើសេនាថាទៅឃាត់ជាប្រញាប់ ។ នាំចូលមកគាល់អញឆាប់ ដូចពាក្យអញប្រាប់កុំអាលសម្លាប់ឡើយ នៃ ។ អញនឹងសួរពាក្យសំដីអោយដឹងសេចក្តី គន្លៀតគន្លោងគំនិត ។ ចូរឯងប្រាប់អញដោយ

ពិតកុំបីឯងបិទមាត់ជិតនៅស្ងៀមធ្វើអ្វី ទោះទាំងវាយយក្សនោះនែឯងលាក់ធ្វើអ្វីប្រាប់អញអោយត្រង់មកណាំ ។ អាធុងស្តាប់ព្រះឱង្ការព្រះមហាក្សត្រាត្រាស់សួរមកខ្លួនឯងនៃ ។ នឹកថាសមអញនឹងក្ស័យជីវិតប្រល័យក្នុងថ្ងៃនេះមែនពិត ។ ទើបទូលទៅទាំងភ័យភិត សេចក្តីនេះពិតគឺចៅសាញ់នោះមែនហើយ ។ ព្រះអង្គត្រាស់បន្ទូលឆ្លើយបើដូច្នោះហើយ យកអាធុងទៅសម្លាប់ ។ នាំវាចេញទៅអោយឆាប់សម្លាប់អោយស្លាប់ឥឡូវនេះអោយឆាប់ណាំ ។ ដ្បិតវាចិត្តចោរមោហាព្រហើនមុសាទុកវាតទៅពុំបាន ។ អាមាត្រស្តាប់បន្ទូលថ្កានក្រោកស្ទុះគ្រប់ប្រាណ ចោមចាប់អាធុងយ៉ាងមាំហើយចងចំណងទាំងប្រាំប្រការ រួចនាំយកទៅកាប់ឯវាលល្បិញ ។ ឯអ្នកផ្ទះវានោះមិញទ្រង់អោយចុះចេញបណ្តេញទៅនៅស្រុកឆ្ងាយ ។ អស់ទ្រព្យសម្បត្តិទាំងឡាយព្រះបាទពណ្ណរាយព្រះអង្គអោយរឹបយកណាំ ។ បញ្ចូលក្នុងឃ្លាំងរាជការញាតិសន្តានវាបញ្ចូលជាអ្នកងារអស់ ។អភិសេកចៅសាញ់នោះស្មោះអោយសោយរាជ្យឆ្ពោះគ្រប់គ្រងនគរនោះណាំ ។ ឯអង្គព្រះបាទក្សត្រាស្តេចដាក់រាជ្យណាំអោយចៅសាញ់គ្រងវិញហោង ។ ឯរាជ្យបុត្រីស្នេហ៍ស្នងព្រះបាទច្បាស់ច្បងអភិសេកជាអង្គជាយា ។

## បទភាគគតិ

ស្តេចរៀបអភិសេក បុត្រទាំងពីរឯក អោយសោយរាជា
មានទាំងរបាំ ច្រៀងរាំនានា សព្វគ្រប់ភាសា
ខ្មែរចាមចិនយួន ។

រៀបលេងដោយសា ស្នំច្រើនក្រៃដេរដាស ពេញពាសតាមក្បួន
ខ្លះលោតអន្ទាក់ ខ្លះលាក់លេងពួន លេងល្បែងដោយខ្លួន
ដោយសាស្នតាមធ្លាប់ ។

ល្ខោនខោលចូលចេញ តាំងចាប់ផ្តើមមិញ គឺស្វាប្រចាប់
ស្វាខ្មៅស្វាសក្បាច់ ល្អចំណាប់ ក្បាច់ស្វាប្រចាប់
ចេញបើករោងណាំ ។

មានទាំងល្ខោនយក្ស រូបរាងទន់ភ្លន់ វិស័យមនុស្សា
ងីវចិនល្អលន់ គួរគន់ទស្សនា ច្រៀងតាមភាសា
ដោយបទភ្លេងគេ ។

មានទាំងងីវយន្ត រូបរាងល្អយន់ ដូចល្ខោនយន្តខ្មែរ
លេងរឿងសាមកុក សៃហាន់បន្លែ លុះព្រះសុរិយា
ព្រលប់ពន់ពេក ។

របាំខេមរា លេងណាំងរចនា ចិនលេងងីវស្បែក
ក្បាច់ក្បូរល្អៗ រៀបអភិសេក ចៅសាញ់ជាឯក
នគរនោះណាំ ។

ទាំងយប់ទាំងថ្ងៃ សប្បាយពេកក្រៃ ប្រាំពីរទិវា
យប់សោតអុជគោម តាមព្រះមន្ត្រា លុះដល់សុរិយា
ភ្លឺស្រាងស្រេចស្រាប់ ។

អភិសេកស្រាប់ហើយ ស្តេចពុំព្រងើយ ប្រដៅក្តីច្បាប់
ដល់បុត្រទាំងពីរ តាមវេណីស្រាប់ អោយដឹងសណ្តាប់
ក្រមក្រឹត្យរាជា ។

ចៅសាញ់សោយរាជ្យ មែនមានអំណាច លើសព្រះបិតា
សឹងបានសាន្តសុខ ឥតទុក្ខភយា ទាំងរាស្ត្រប្រជា
ឥតមានទុក្ខសោក ។

ខ្លះលក់ទំនិញ ដូចពីមុនមិញ ទិញគ្នាទៅមក
គគ្រឹកគគ្រេង រអែងរអោក ទិញដូរគ្នាយក
តាមធម្មតាហោង ។ ។

ឥតទុក្ខឥតភ័យ រកស៊ីសព្វថ្ងៃ សប្បាយឥតហ្មង
ចៅសាញ់សោយរាជ្យ អំណាចកន្លង ពុំផ្តើលដល់ម្តង
សុខស្ងប់ក្រៃ ។

រឿងព្រេងនិទាន ដែលអញខ្ញុំបាន នាំមកចារចែង
តាមបែបទំនង ចាស់ផងថ្លាថ្លែង អស់ប៉ុណ្ណោះឯង
សូរេចចប់ហោង ។

**គូគេចមិនរួច អាយុមិនអស់មិនស្លាប់**